ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :.........១៤០/២៤..............ក.ប/ស.ណ.ន.អ.ក

# សេចក្តីណែនាំ
# ស្តីពី
# វិធានការសុវត្ថិភាព និងសុខភាពការងារ
# សម្រាប់កម្មករនិយោជិតក្នុងករណីមានគ្រោះជំនន់ទឹកភ្លៀង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ដែលស្ថិតក្នុងដែនអនុវត្តច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីបង្ការហានិភ័យដែលអាចកើតមានឡើងជាយថាហេតុដោយសារគ្រោះជំនន់ទឹកភ្លៀងនៅក្នុងភូមិសាស្ត្រដែលមានសហគ្រាស គ្រឹះស្ថាន និងកន្លែងស្នាក់នៅរបស់កម្មករនិយោជិត ក្រសួងសូមធ្វើការណែនាំដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

## ក. ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន

១. ត្រូវតាមដានស្ថានភាពទឹកជំនន់ជាប្រចាំនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។

២. ត្រូវរៀបចំបង្កើតក្រុមការងារ និងត្រៀមផែនការសង្គ្រោះ មធ្យោបាយការពារ និងជម្លៀសកម្មករនិយោជិត ក្នុងករណីមានទឹកជំនន់។

៣. ត្រូវធ្វើការត្រួតពិនិត្យបណ្តាញអគ្គិសនីឱ្យបានត្រឹមត្រូវ និងសមស្របតាមលក្ខណៈបច្ចេកទេសសុវត្ថិភាព សម្រាប់បង្ការ និងបញ្ចៀសនូវបញ្ហាចាំបាច់ចំពោះមុខទៅតាមកាលៈទេសៈជាយថាហេតុណាមួយ។

៤. ត្រូវមានវិធានការរៀបចំការសង្គ្រោះបឋម និងវិធីសាស្ត្រជួយសង្គ្រោះ ក្នុងករណីឆក់ចរន្តអគ្គិសនី លង់ទឹក សត្វទិច ចឹក ឬខាំ។

៥. ត្រូវទុកដាក់វត្ថុធាតុដើម សម្ភារសំខាន់ៗ និងសារជាតុគីមីឱ្យបានត្រឹមត្រូវ ផុតពីទឹក និងមានសុវត្ថិភាព ជាពិសេសវត្ថុធាតុដើម និងសារជាតុគីមីដែលមានប្រតិកម្មជាមួយទឹក។

៦. ត្រូវរៀបចំដាក់ស្លាកសញ្ញាហាមឃាត់នៅកន្លែងដែលមានគ្រោះថ្នាក់ ទឹកជន់លិច ឬហូរខ្លាំង។

៧. ត្រូវត្រៀមស្បៀងអាហារ និងទឹកស្អាត សម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ អំឡុងពេលរង់ចាំក្រុមជួយសង្គ្រោះទៅដល់ ក្នុងករណីកម្មករនិយោជិតជាប់គាំងក្នុងសហគ្រាស គ្រឹះស្ថាន នៅពេលមានទឹកជំនន់។

៨. ត្រូវត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធសុវត្ថិភាពផ្សេងៗ សម្អាតបរិវេណសហគ្រាស គ្រឹះស្ថាន និងធ្វើអនាម័យបង្គន់ឡើងវិញ ដើម្បីជៀសវាងជំងឺឆ្លងផ្សេងៗ ក្រោយពេលទឹកជំនន់ស្រកចុះ។

៩. ត្រូវអប់រំផ្សព្វផ្សាយដល់កម្មករនិយោជិតអំពីវិធានការសុវត្ថិភាព និងសុខភាពការងារពាក់ព័ន្ធនឹងផែនការឆ្លើយតបនៅពេលមានអាសន្នរបស់សហគ្រាស គ្រឹះស្ថាន ដើម្បីការពារសុវត្ថិភាពកម្មករនិយោជិតនៅពេលមានទឹកជំនន់កើតឡើង។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

១០. ត្រូវចូលរួមអនុវត្តឱ្យបានហ្មត់ចត់តាមវិធានការនានារបស់អាជ្ញាធរមូលដ្ឋាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសហការឱ្យបានពេញលេញជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីមានការណែនាំជាក់ស្តែង។

**ខ. កម្មករនិយោជិត**

១. ត្រូវប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុជាអាទិ៍ ការឆក់ចរន្តអគ្គិសនី លង់ទឹក សត្វទិច ចឹក ឬខាំ។

២. ត្រូវចូលរួមអនុវត្តជាចាំបាច់តាមការណែនាំរបស់និយោជក និងអាជ្ញាធរពាក់ព័ន្ធ។

៣. ត្រូវផ្តល់ព័ត៌មានអំពីស្ថានភាពសុវត្ថិភាព និងសុខភាពរបស់ខ្លួន ទៅកាន់និយោជកជាប្រចាំ ក្នុងអំឡុងពេលឈប់សម្រាកដោយសារគ្រោះទឹកជំនន់។

៤. ត្រូវចូលរួមអនុវត្តឱ្យបានហ្មត់ចត់តាមវិធានការនានារបស់អាជ្ញាធរមូលដ្ឋាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសហការឱ្យបានពេញលេញជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីមានការណែនាំជាក់ស្តែង។

ក្នុងករណីចាំបាច់ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ត្រូវជូនដំណឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ក្រុមតេឡេក្រាម "សម្រាប់និយោជក" https://t.me/EmployerChat និងក្រុមតេឡេក្រាម "សម្រាប់កម្មករនិយោជិត" https://t.me/KhmerWorkerChat ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីចុះវាយតម្លៃកម្រិតហានិភ័យដែលអាចកើតមានឡើង ចំពោះសុវត្ថិភាពកម្មករនិយោជិតក្នុងអំឡុងពេលមានទឹកជំនន់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវ និងធានាបាននូវប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ៦រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

"សម្រាប់និយោជក"

"សម្រាប់កម្មករនិយោជិត"

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ